**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

លេខៈ ៧៤០១១ អយក.ហវ

ថ្ងៃព្រហស្បតិ៍ ២កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០២៤

## ជម្រាបជូន

**-លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**-លោក លោកស្រីប្រធានការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ**

**-លោក លោកស្រីនាយក នាយិកា នាយកគ្រឹះស្ថានមត្តេយ្យសិក្សានិងចំណេះទូទៅសាធារណៈ**

**កម្មវត្ថុ ៖** ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា (EFMS) លើមុខងារគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ(SOF) ចាប់ពីឆ្នាំ២០២៤ តទៅ។

**យោង ៖** -លិខិតលេខ១៣៩០ អយក.ហវ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា

-លិខិតលេខ១៤១០ អយក.ហវ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោក លោកស្រីប្រធាន នាយក នាយិកា ជ្រាបថា៖ កាលពីឆ្នាំ២០១៩ កន្លងមក ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ(SOF) ដែលមានលក្ខណៈជា Desktop Application (Offline) ជូនគ្រឹះស្ថានសិក្សាសាធារណៈទូទាំងប្រទេស ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត តាមស្មារតីនៃលិខិតលេខ១៣៩០ អយក.ហវ ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០១៩។

ក្នុងស្ថានភាពនៃការវិវត្តឥតឈប់ឈរនៃបច្ចេកវិទ្យាឌីជីថល ក្រសួងបានធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា(EFMS) លើមុខងារគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ (SOF) ឱ្យទៅជាលក្ខណៈ Web Application(Online) ដោយបានពង្រីកវិសាលភាពមុខងារប្រតិបត្តិការថ្មីៗជាច្រើនក្នុងប្រព័ន្ធឱ្យមានលក្ខណៈទូលំទូលាយនិងប្រសើរជាងមុន ជាពិសេសពាក់ព័ន្ធទៅនឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (BSP) ដោយផ្សារភ្ជាប់ជាមួយការរៀបចំផែនការថវិកាប្រចាំឆ្នាំនិងផែនការប្រតិបត្តិប្រចាំឆ្នាំ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ កិច្ចបញ្ជិកាគណនេយ្យសម្ភារៈ ការផ្តល់ព័ត៌មានត្រឡប់របស់សាលារៀនសាធារណៈលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងការរៀន និងបង្រៀន។ល។ ដោយបានអភិវឌ្ឍលើមុខងារទាំងនេះ ក្នុងគោលបំណងបង្កលក្ខណៈងាយស្រួលជូនអ្នក



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ប្រើប្រាស់សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ ឱ្យប្រកបដោយគណនេយ្យភាព ប្រសិទ្ធភាព តម្លាភាព និងភាពទាន់ពេលវេលា ព្រមទាំងឱ្យសង្គតិភាពទៅនឹងនីតិវិធីនិងការងារកំពុងអនុវត្តបច្ចុប្បន្ន ហើយក៏បានជួយសម្រួលការងារជាអតិបរមាជូនមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុឱ្យកាន់តែប្រសើរជាងមុន។ ក្នុងន័យនេះ ក្រសួងសូមដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា(EFMS)លើមុខងារគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ (SOF) ជូនគ្រឹះស្ថានសិក្សាសាធារណៈ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តចាប់ពីឆ្នាំ២០២៤ តទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រីប្រធាន នាយក នាយិកា ចូលរួមចាត់ចែងផ្សព្វផ្សាយ និងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ តាមការគួរ។

សូម លោក លោកស្រីប្រធាន នាយក នាយិកា ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូនៈ**

- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
  " ដើម្បីជ្រាបជាព័ត៌មាន "
- កាលប្បវត្តិ
- ឯកសារ .នា. ហិរញ្ញវត្ថុ